បោះពុម្ព និងផ្សព្វផ្សាយ

ដោយ គ.ជ.ប

ឆ្នាំ២០១៨


អាសយដ្ឋាន ៖ ទីស្តីការ គ.ជ.ប លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

E-mail : necinfo@forum.org.kh

គេហទំព័រ ៖ www.necelect.org.kh, www.voterlist.org.kh

Facebook : National Election Committee គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត


**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**(គ.ជ.ប)**



# សៀវភៅ
# សម្រាប់
# អ្នកបោះឆ្នោត

**ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤**

**ថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨**



# ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
# នីតិកាលទី៤ ឆ្នាំ២០១៨




*កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ប្រព្រឹត្តទៅនៅ**ថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨**។*



សមាជិកព្រឹទ្ធសភា សម្រាប់នីតិកាលទី៤ មានចំនួន ៦២[១]រូប ក្នុងនោះ ៖

- សមាជិកព្រឹទ្ធសភាចំនួន ២ រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ
- សមាជិកព្រឹទ្ធសភាចំនួន ២ រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប[២]
- សមាជិកព្រឹទ្ធសភាចំនួន ៥៨ រូបទៀត ត្រូវបានជ្រើសតាំងតាមការបោះឆ្នោតអសកល មិនចំពោះតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដែលក្នុងនោះអាសនៈត្រូវបានបែងចែកតាមភូមិភាគ ដូចខាងក្រោម ៖
  - ភូមិភាគទី ១ រាជធានីភ្នំពេញ **មាន ៦ អាសនៈ**
  - ភូមិភាគទី ២ ខេត្តកំពង់ចាម និង ខេត្តត្បូងឃ្មុំ **មាន ៨ អាសនៈ**
  - ភូមិភាគទី ៣ ខេត្តកណ្ដាល **មាន ៥ អាសនៈ**
  - ភូមិភាគទី ៤ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្ដរមានជ័យ និងខេត្តប៉ៃលិន **មាន ១០ អាសនៈ**

---

[១] ព្រឹទ្ធសភា មានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភា ។

[២] ដោយប្រៀបៈ មានន័យថា លើសសំឡេងឆ្នោតមួយសំឡេង ។

- *ភូមិភាគទី ៥* *ខេត្តតាកែវ ខេត្តកំពត និង*
  *ខេត្តកែប* **មាន ៧ អាសនៈ**
- *ភូមិភាគទី ៦* *ខេត្តព្រៃវែង និង*
  *ខេត្តស្វាយរៀង* **មាន ៧ អាសនៈ**
- *ភូមិភាគទី ៧* *ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង*
  *ខេត្តពោធិ៍សាត់ ខេត្តកោះកុង និង*
  *ខេត្តព្រះសីហនុ* **មាន ៩ អាសនៈ**
- *ភូមិភាគទី ៨* *ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ*
  *ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និង*
  *ខេត្តមណ្ឌលគិរី* **មាន ៦ អាសនៈ**

# អ្នកបោះឆ្នោត និងអង្គបោះឆ្នោត




តំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងអស់ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌ រាជធានី ខេត្តចំណុះភូមិភាគនីមួយៗ ត្រូវបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

តំណាងរាស្ត្រក្នុងតំណែងម្នាក់ៗ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងម្នាក់ៗ មានសិទ្ធិចុះឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយនៅទីប្រជុំជនរាជធានី ខេត្តតែមួយគត់ចំណុះភូមិភាគពាក់ព័ន្ធ ។

# ការិយាល័យចុះឈ្មោះបោះឆ្នោត




ការិយាល័យចុះឈ្មោះបោះឆ្នោតចំនួនមួយ ត្រូវបានកំណត់សម្រាប់អង្គបោះឆ្នោតដែលជាតំណាងរាស្ត្រ និងការិយាល័យចុះឈ្មោះបោះឆ្នោតចំនួនមួយ ត្រូវបានកំណត់សម្រាប់អង្គបោះឆ្នោតដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឃុំ សង្កាត់នីមួយៗ ។ ការិយាល័យចុះឈ្មោះបោះឆ្នោត គឺជាការិយាល័យស្ថិតនៅមួយកន្លែង ។



- ការិយាល័យចុះឈ្មោះបោះឆ្នោតសម្រាប់តំណាងរាស្ត្រក្នុងតំណែង ត្រូវមានទីតាំងនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា ។
- ការិយាល័យចុះឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង ត្រូវមានទីតាំងនៅសាលាឃុំ សង្កាត់ ឬទីតាំងណាមួយសមស្របក្នុងឃុំ សង្កាត់ ។

# លក្ខខណ្ឌសម្រាប់អ្នកបោះឆ្នោត




ដើម្បីបោះឆ្នោតបាន អ្នកមានសិទ្ធិបោះឆ្នោត ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត
- មានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត
- ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

# ដំណើរប្រព្រឹត្តទៅនៃការបោះឆ្នោត




*ការិយាល័យបោះឆ្នោតចាប់ផ្តើមបើកឱ្យអ្នកបោះឆ្នោតចូលទៅបោះឆ្នោតចាប់ពី**ម៉ោង ៧:០០ នាទីព្រឹក ដល់ម៉ោង ៣:០០ នាទីរសៀល** ។ ការបោះឆ្នោតត្រូវធ្វើតែ ១ថ្ងៃ ។*



នៅពេលទៅដល់ការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតត្រូវទៅរកមើលឈ្មោះរបស់ខ្លួនក្នុងបញ្ជីបោះឆ្នោត ដែលត្រូវបានបិទនៅមុខការិយាល័យបោះឆ្នោត ដើម្បីឱ្យប្រាកដថា ឈ្មោះរបស់ខ្លួនស្ថិតក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។






អ្នកបោះឆ្នោតស្វែងរកឈ្មោះក្នុងបញ្ជីបោះឆ្នោត ដែលបិទនៅមុខការិយាល័យបោះឆ្នោត

នៅពេលបានចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតត្រូវទៅជួបលេខាធិការមុនគេ ។

- លេខាធិការត្រួតពិនិត្យម្រាមដៃអ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថា គ្មានស្នាមទឹកខ្មៅលុបមិនជ្រះ ។

- *អ្នកបោះឆ្នោត ត្រូវប្រគល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ឱ្យលេខាធិការ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីបោះឆ្នោត ។ ក្នុងករណីនេះ អ្នកបោះឆ្នោតត្រូវប្រាប់លេខរៀងរបស់ខ្លួនទៅលេខាធិការ ដើម្បីងាយស្រួលក្នុងការរកឈ្មោះក្នុងបញ្ជីបោះឆ្នោត ។*

បន្ទាប់មក លេខាធិការប្រាប់ឲ្យ
អ្នកបោះឆ្នោត គូសសញ្ញាធិចទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោត
នៅក្នុងបញ្ជីបោះឆ្នោត ដើម្បីបញ្ជាក់ការបានមកបោះឆ្នោត
របស់អ្នកបោះឆ្នោត ។






**លេខាធិការពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត**

បន្ទាប់មក  លេខាធិការប្រាប់ឱ្យអ្នកបោះឆ្នោតទៅទទួលយកសន្លឹកឆ្នោតពីអនុប្រធាន ដែលនៅអង្គុយខាងស្ដាំដៃគាត់ ។






**អនុប្រធានបោះត្រាសម្គាល់នៅផ្នែកខាងខ្នងនៃសន្លឹកឆ្នោត**
**និងប្រគល់សន្លឹកទៅអ្នកបោះឆ្នោត**

បន្ទាប់មក អ្នកបោះឆ្នោត
ត្រូវដើរទៅកាន់បន្ទប់សម្ងាត់ណាមួយដែលទំនេរ
ដើម្បីចូលទៅគូសសន្លឹកឆ្នោត ។

នៅក្នុងបន្ទប់សម្ងាត់នេះ
គ្មានអ្នកណាដឹងថា អ្នកបោះឆ្នោតគូសសញ្ញា
គាំទ្រឱ្យគណបក្សណាមួយឡើយ ។






អ្នកបោះឆ្នោតគូសសន្លឹកឆ្នោតក្នុងបន្ទប់សម្ងាត់

អ្នកបោះឆ្នោត ត្រូវគូសសញ្ញាគាំទ្រមួយ
នៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយតែ ១គត់
ដែលអ្នកពេញចិត្ត ដោយប្រើប៊ិកដែលមានក្នុងបន្ទប់សម្ងាត់ស្រាប់
ឬក៏អាចប្រើប៊ិកផ្ទាល់ខ្លួន លើកលែងតែខ្មៅដៃ ។



## ការគូសសន្លឹកឆ្នោតដែលត្រឹមត្រូវ




## ការគូសសន្លឹកឆ្នោតដែលមិនត្រឹមត្រូវ



មុននឹងចេញពីបន្ទប់សម្ងាត់
អ្នកបោះឆ្នោតត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើម
រួចដើរទៅកាន់តុដាក់ហិបឆ្នោត លើកសន្លឹកឆ្នោតដែល
បត់រួចហើយ និងមានត្រាសម្ងាត់នៅខាងខ្នងបង្ហាញ
សមាជិកទី១ ដែលនៅក្បែរនោះ រួចស៊កសន្លឹកឆ្នោតតាម
ប្រឡោះតូចចូលទៅក្នុងហិបឆ្នោត ។





ការស៊កសន្លឹកឆ្នោតចូលទៅក្នុងហិបឆ្នោត






ជូបសមាជិកទី១ ដើម្បីជ្រលក់ម្រាមចង្អុលដៃស្តាំ
ទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ







អ្នកបោះឆ្នោតដើរចេញពីការិយាល័យបោះឆ្នោត


១
យើងត្រូវដឹងថា សន្លឹកឆ្នោតយើង
គឺជាសន្លឹកឆ្នោតសម្ងាត់ គ្មានជនណាម្នាក់ដឹងថា
យើងបោះឆ្នោតជូនគណបក្សនយោបាយណាមួយឡើយ ។
បើមានជនណាម្នាក់មកសួរយើងថា
បោះឆ្នោតឱ្យគណបក្សណាមួយនោះ យើងមិនត្រូវ
ប្រាប់គេឡើយ ព្រោះវាជាការសម្ងាត់របស់យើង។
២
អូហ៍.....ខ្ញុំយល់ហើយ !

# បោះពុម្ពផ្សាយដោយ

**គ.ជ.ប**

# ឆ្នាំ២០១៨